# បញ្ហាកង្វល់របស់ អ៊ុំ ខុន សម្រាប់ជីវិតជាអ្នកកសិករ

*ចាន ប្រាថ្នាៈ មជ្ឈមណ្ឌលឯកសារកម្ពុជា*

*ពិនិត្យ និង កែសម្រួលៈ ឆាំង យុ*

*(២៩ ខែមេសា ឆ្នាំ២០១៤)*



លោកពូអ៊ុំខុនមានវ័យ៥១ឆ្នាំប្រពន្ធឈ្មោះ កែវ ធី មានកូនចំនួន ៣នាក់ បច្ចុប្បន្នរស់នៅជិតទីរួមស្រុកព្រៃកប្បាស ខេត្តតាកែវ ។ ជារៀងរាល់ឆ្នាំ នៅរដូវធ្វើស្រែប្រាំង អ៊ុំ ខុន ជាមួយប្រពន្ធ ត្រូវរេចខ្ចប់ ចាន ឆ្នាំង ភួយ មុង កន្ទេល ។ល ។ ដើម្បីទៅធ្វើស្រែនៅខាងត្បូងភ្នំដា ជិតព្រំប្រទល់វៀតណាម ដោយសម្រាកនៅទីនោះ ២ ទៅ ៣ខែ ទើបមកផ្ទះម្តង ។ អ៊ុំ ខុន កំពុងអង្គុយសម្រាកនៅក្នុងកូនខ្ទមរបស់គាត់ ដែលសង់សម្រាប់ស្នាក់នៅធ្វើស្រែប្រាំងរបស់គាត់ ។

នៅក្នុងកិច្ចសន្ទនាមួយសន្ទុះធំដោយសួរនាំអំពីជីវិតជាកសិករ អ៊ុំ ខុន ពុំបានត្អូញត្អែរអំពីការលំបាកវេទនារបស់គាត់បន្តិចណាសោះឡើយ ក្រៅពីបញ្ហាដែលគាត់កំពុងតែប្រឈមហើយដែលគាត់មានការលំបាកក្នុងការដោះស្រាយ ។ អ្វីដែលរូបគាត់មានកង្វល់ខ្លាំងបំផុតនោះគឺ ការប្រើប្រាស់ថ្នាំពុលសម្រាប់បាញ់ការពារស្រូវ ការប្រើប្រាស់ជីគីមី និង ការលក់ផលស្រូវរបស់គាត់ ។

## ការប្រើប្រាស់ថ្នាំពុលសម្រាប់ការពារដំណាំស្រូវ

នៅពេលចាប់ផ្តើមនិយាយអំពីបញ្ហានេះ អ៊ុំ ខុន បានរំឭកទៅដល់ប្រពន្ធរបស់គាត់ឈ្មោះ កែវ ធី ដែលទើបតែទទួលមរណៈភាពនាពេលថ្មីៗនេះ ដោយសារកម្រិតជាតិពុលនៅក្នុងខ្លួនឡើងដល់ ១៧៧០ ។ កម្រិតជាតិពុលនេះបណ្តាលមកពីការប្រើប្រាស់ជីគីមី និង ថ្នាំពុល ដែលត្រូវប្រើសម្រាប់បង្កើនការរីកធំធាត់ និងការពារដំណាំស្រូវ ។ អ៊ុំ ខុន បញ្ជាក់ថា ហេតុការណ៍នេះបានបង្ករឲ្យគាត់មានការព្រួយបារម្ភយ៉ាងខ្លាំង ដោយសាររូបគាត់ ក៏ដូចជាកសិករផ្សេងៗទៀត ត្រូវប្រឈមនឹងការប្រើប្រាស់ជីគីមី និងថ្នាំពុលទាំងនេះជាប្រចាំសម្រាប់របរកសិកម្មរបស់គាត់ ។ នៅពេលសួរថា តើរូបគាត់ ក៏ដូចជាកសិករផ្សេងៗទៀត អាចកាត់បន្ថយការប្រើប្រាស់ថ្នាំពុលទាំងនោះបានដែរឬទេ? ចម្លើយរបស់គាត់ គឺថា "មិនអាច" ផ្ទុយទៅវិញរឹតតែបង្កើនការប្រើប្រាស់ថែមទៀត ។ ការបង្កើនការប្រើប្រាស់នេះ គឺដើម្បី

ឆ្លើយតបទៅនឹងការកើនឡើងនៃប្រភេទជំងឺ ដែលអាចបំផ្លាញផលដំណាំស្រូវរបស់គាត់ ។ អ៊ុំ ខុន បានរៀបរាប់ថា កាលពីមុនដំណាំស្រូវរបស់គាត់ពុំសូវមានជំងឺឡើយ ដូច្នេះតម្រូវការប្រើប្រាស់ថ្នាំពុល គឺមានតិចតួចប៉ុណ្ណោះ ។ ប៉ុន្តែបច្ចុប្បន្ន ប្រភេទស្មៅ ប្រភេទសត្វល្អិត និង ប្រភេទជំងឺ ដែលមកបំផ្លាញដំណាំស្រូវរបស់គាត់មានកាន់តែច្រើន ដូច្នេះតម្រូវឲ្យគាត់ត្រូវតែប្រើប្រាស់ថ្នាំពុលច្រើនឡើងៗ ដើម្បីការពារដំណាំស្រូវ បើពុំនោះទេមិនទទួលបានផលឡើយ ។ នៅពេលសួរថា *“ពេល ពូ ដឹងថាប្រពន្ធ ពូ ស្លាប់ដោយសារជាតិពុល តើ ពូ មានការភ័យព្រួយដែរ ឬទេ ពេល ពូ បាញ់ថ្នាំ?”* អ៊ុំខុន ឆ្លើយថា *“អ្ហ! ភ័យ! តែមិនដឹងធ្វើម៉េច! បើមិនបាញ់ សត្វល្អិតវាស៊ីស្រូវយើងអស់ខូចចោលទទេ បានអីហូប?”* ។ កូនស្រីគាត់ដែលឈរនៅក្បែរនោះដែរបានបន្ទរបន្ថែមថា *“គេបាញ់គ្រប់តែគ្នាហ្នឹង ។ បើគេបាញ់ ហើយយើងអត់បាញ់ ចឹងសត្វល្អិតអស់ហ្នឹងវាមកស៊ីរបស់យើង ។ ដូច្នេះ យើងត្រូវតែបាញ់”* ។ អ៊ុំ ខុន មានការងឿងឆ្ងល់ថាហេតុអ្វីបានជាប្រភេទស្មៅ សត្វល្អិត និងជំងឺទាំងនោះ កើតមានកាន់តែច្រើនឡើងៗ ដែលកាលពីមុនមិនធ្លាប់មានទាល់តែសោះ ។ គាត់មានការព្រួយបារម្ភអំពីបញ្ហានេះយ៉ាងខ្លាំង ដោយសារគាត់នឹងត្រូវចំណាយកាន់តែច្រើនសម្រាប់ការប្រើប្រាស់ថ្នាំពុល និង ត្រូវប្រឈមទៅនឹងការប៉ះពាល់សុខភាពកាន់តែខ្លាំង ។

### ការប្រើប្រាស់ជីគីមី

លោកពូ អ៊ុំ ខុន បានលើកឡើងថា ក្រៅពីការប្រើប្រាស់ថ្នាំពុល ការធ្វើស្រែប្រាំងរបស់គាត់កំពុងប្រឈមយ៉ាងខ្លាំងទៅលើការប្រើប្រាស់ជីគីមី ។ ការប្រើប្រាស់ជីគីមីនេះ ត្រូវបង្កើនបរិមាណជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ(ទំហំផ្ទៃដីដដែល) ដើម្បីអាចរក្សាស្ថេរភាពទិន្នផលស្រូវសម្រាប់ឆ្នាំនីមួយៗ ។ អ៊ុំ ខុន ធ្វើការពន្យល់ដោយផ្តល់ឧទាហរណ៍ថា ប្រសិនបើឆ្នាំនេះគាត់ប្រើជីគីមីចំនួន ៥ បាវ សម្រាប់ផ្ទៃដី ១ ហិកតា នោះឆ្នាំក្រោយគាត់ត្រូវប្រើជីគីមីពី ៦ ទៅ ៧បាវ សម្រាប់ទំហំផ្ទៃដីដដែលនេះ បើពុំនោះទេផលស្រូវនឹងមានការធ្លាក់ចុះ ។ ដូច្នេះ ការចំណាយរបស់គាត់កាន់តែមានការកើនឡើង ហើយដីកាន់តែបាត់បង់ជីជាតិ(ដីហិល) ។

### ការលក់ផលស្រូវ

ជារៀងរាល់ឆ្នាំ អ៊ុំ ខុន លក់ផលស្រូវរបស់គាត់នៅនឹងស្រែភ្លាមៗ ពោលគឺមិនដឹកជញ្ជូនមកផ្ទះឡើយ ពីព្រោះស្រែរបស់គាត់នៅឆ្ងាយពីផ្ទះពេក ។ គាត់ត្រូវគរស្បោងស្រូវរបស់គាត់ទុកនៅក្នុងស្រែ ឬទុកនៅលើខ្នងទំនប់រង់ចាំរហូតមានឈ្មួញទៅទិញ ។ ឈ្មួញទៅទិញស្រូវរបស់គាត់ ភាគច្រើនជាឈ្មួញវៀតណាម ចំណែកឈ្មួញស្រូវជនជាតិខ្មែរមិនសូវមានឡើយ ។ អ៊ុំ ខុន និង ប្រជាកសិករផ្សេងៗទៀតដែលធ្វើស្រែនៅជិតគ្នានោះបានបញ្ជាក់ទៀតថា ដោយសារការលក់ផលស្រូវរបស់គាត់ត្រូវពឹងផ្អែកទៅលើឈ្មួញវៀតណាម ដូច្នេះពេលណាឈ្មួញវៀតណាមមិនមកទិញ ឬនាំគ្នាបញ្ចុះតម្លៃ(បង្អាប់តម្លៃ) ស្រូវនោះ គឺគាត់មានការលំបាកជាខ្លាំង ។ ពេលខ្លះគាត់ត្រូវបង្ខំចិត្តលក់ផលស្រូវរបស់គាត់ក្នុងតម្លៃថោក ។

បើតាមការសាកសួរប្រជាកសិករផ្សេងៗទៀត ដែលធ្វើស្រែនៅតំបន់នោះ គាត់ក៏កំពុងមានក្តីកង្វល់អំពីបញ្ហាទាំងនេះដែរ ។ គាត់កំពុងតែប្រឈមជាមួយបញ្ហាទាំងនេះ ហើយមិនដឹងត្រូវដោះស្រាយយ៉ាងណាឡើយ ។ កត្តាទាំងនេះ បានបង្កឲ្យគាត់មានការព្រួយបារម្ភយ៉ាងខ្លាំង សម្រាប់ជីវិតរបស់គាត់ដែលប្រកបរបរកសិកម្ម ។ ដោយសារប្រជាជនកម្ពុជាភាគច្រើនប្រកបរបរកសិកម្ម បញ្ហាទាំងនេះគឺជាចំណុចស្នូលដែលត្រូវយកមកពិភាក្សា និងដោះស្រាយជាបន្ទាន់ ។


ប្រជាកសិករកំពុងឈប់សម្រាកបន្ទាប់ពីបរិភោគអាហារថ្ងៃត្រង់រួច ។